នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Feb-2012, 15:39
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅលើឯកសាររបស់ នួន ជា ដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅដំណាក់កាលដំបូងនៃការជំនុំជម្រះ**

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS
លោក គង់ សំអុន

លោក Arthur VERCKEN
លោក Jacques VERGÈS

## I. សេចក្តីផ្តើម

១- នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ ក្រុមមេធាវីការពារក្តី នួន ជា ("មេធាវីការពារក្តី") បានដាក់ *បញ្ជីឯកសាររបស់ នួន ជា ដែលត្រូវដាក់ នៅដំណាក់កាលដំបូងនៃការជំនុំជម្រះ នៅចំពោះមុខអង្គជំនុំជម្រះ* ("បញ្ជីឯកសារ")[1]។ បញ្ជីឯកសារនេះ ដាក់បញ្ចូលឯកសារចំនួន៣៥ ដែលក្នុងចំនួននេះ គ្មានឯកសារណាមួយត្រូវបានស្នើឡើងដោយមេធាវីការពារក្តីពីមុននោះទេ ហើយក្នុងចំនួននេះ ក៏មានឯកសារចំនួន១២ គឺជា "ឯកសារថ្មី" ដែលស្របទៅតាមខ្លឹមសារវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង[2]។ មេធាវីការពារក្តីស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ទទួលយកឯកសារទាំងអស់ដែលមាននៅក្នុងបញ្ជីឯកសារ ដោយខ្លួនអះអាងថា ឯកសារទាំងនេះមានការពាក់ព័ន្ធ និងមានសញ្ញាបង្ហាញអំពីភាពជឿទុកចិត្តបានគ្រប់គ្រាន់។ ជាការបន្ថែម មេធាវីការពារក្តីអះអាងថា ទោះបីជាខ្លួនមិនបានអនុវត្តតាមដីកាសម្រេចរបស់អង្គជំនុំជម្រះពីមុនមកក្នុងការដាក់បញ្ជីឯកសារ និងបានជូនដំណឹងពីចេតនារបស់ខ្លួនអំពីការពឹងផ្អែកទៅលើឯកសារទាំងនេះក្តី ក៏ការណ៍នេះមិនបានច្រានចោលជាមុនមិនឲ្យធ្វើដូច្នេះបានដែរ ក្នុងដំណាក់កាលនេះ ដោយសារថា ច្បាប់កម្ពុជាមិនបានបញ្ចូល "លក្ខខណ្ឌតម្រូវនៃការជូនដំណឹងជាមុន"[3] នេះឡើយ។

២- ជាការឆ្លើយតប សហព្រះរាជអាជ្ញាសន្និដ្ឋានថា ដោយសារចេតនារបស់មេធាវីការពារក្តីមិនចង់អនុវត្តតាមសេចក្តីបង្គាប់របស់អង្គជំនុំជម្រះពីមុន ក្នុងការដាក់បញ្ជីឯកសារ ស្របតាមវិធាន៨០(៣) និងការខកខានរបស់ខ្លួនមិនបានបំពេញតាមលក្ខខណ្ឌតម្រូវ ដូចមានចែងក្នុងវិធាន៨៧(៤) ទាក់ទិននឹងឯកសារថ្មី ដែលខ្លួនបានស្នើឡើង អង្គជំនុំជម្រះសាលាដំបូងគួរតែបដិសេធចោលបញ្ជីឯកសារនេះ។

---

[1] **E131/1/13** បញ្ជីឯកសារដែលត្រូវដាក់នៅដំណាក់កាលដំបូងនៃការជំនុំជម្រះ នៅចំពោះមុខអង្គជំនុំជម្រះ, ៣១ មករា ២០១២ (បានជូនដំណឹងនៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១២) និងមានភ្ជាប់មកជាមួយនូវឧបសម្ព័ន្ធ១ E131/1/13.1 (បានជូនដំណឹងនៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២)។ ចម្លើយតបនាពេលបច្ចុប្បន្ននេះបានដាក់ក្នុងរយៈពេលមួយកំណត់ដូចដែលមានចែងនៅក្នុងសេចក្តីណែនាំអនុវត្តចំណុច៨.៣ និងចំណុច៨.៥ ដែលគណនាគិត១០ថ្ងៃ ចាប់ពីថ្ងៃបានទទួលការជូនដំណឹងនៃឧបសម្ពន្ធ ១។

[2] គេបានកត់សម្គាល់ថា ឯកសារទាំង១៤នៅក្នុងបញ្ជីឯកសារដែលមិនទាន់មានលេខនៅក្នុងសំណុំរឿង។ ទោះបីជាយ៉ាងណាក៏ដោយ ឯកសារចំនួន២ ក្នុងចំណោំឯកសារចំនួន១៤នេះ (ឯកសារ ២២-២៣) ត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ដាក់ជូនកាលពីខែមេសា ឆ្នាំ២០១១ មុនបើកសវនាការ។ ដូច្នេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ឯកសារនោះមិនមែនជាឯកសារថ្មីស្របតាមខ្លឹមសារវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងទេ។ សូមបញ្ជាក់បន្ថែមទៀតថា ឯកសារចំនួន៩ ក្នុងចំណោមឯកសារ១២ អាចត្រូវបានបញ្ចូលទៅក្នុងសំណុំរឿងជាឧបសម្ពន្ធនៃបញ្ជីឯកសារ។ សូមមើលឯកសារ 24-29, 32-33, និង 35 នៅលើបញ្ជីឯកសារដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿងដែលមានឯកសារយោងដូចតទៅនេះ E131/1.13.2; E131/1.13.12; E131/1.13.3; E131/1.13.4; E131/1.13.5; E131/1.13.6; E131/1.13.8; E131/1.13.9 និង E131/1.13.11 ។

[3] **E131/1/13** បញ្ជីឯកសារ, កំណត់សម្គាល់*ខាងដើម* លេខ១ ត្រង់កថាខ័ណ្ឌទី២-៧។

ទោះជាយ៉ាងនេះក្តី សហព្រះរាជអាជ្ញាសង្កេតឃើញថា មានឯកសារ ១៤ ក្នុងចំនួនឯកសារដែលមាននៅក្នុងបញ្ជីឯកសារនេះ បានដាក់រួចហើយ ឬក៏ធ្លាប់បានស្នើឲ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះ តាមសំណើរបស់សហព្រះរាជអាជ្ញា ឬដោយអង្គជំនុំជម្រះតាមញត្តិស្នើសុំផ្ទាល់ខ្លួន។ ឯកសារទាំងនេះត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ពន្ធ ក ក្នុងចម្លើយតបនេះ។ សហព្រះរាជអាជ្ញាសូមបញ្ជាក់ថា សហព្រះរាជអាជ្ញានឹងមិនជំទាស់នឹងមេធាវីការពារក្តី ក្នុងការប្រើប្រាស់ឯកសារជាក់លាក់ទាំងនេះ នៅពេលសវនាការជំនុំជម្រះឡើយ។

## II. ប្រវត្តិពាក់ព័ន្ធ

៣- នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យភាគីដាក់បញ្ជីឯកសារដែលខ្លួនមានបំណងពឹងផ្អែកនៅពេលសវនាការជំនុំជម្រះ[4]។ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ គឺនៅក្នុងអំឡុងពេលនៃសវនាការបឋមសម្រាប់សំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យភាគីកំណត់អត្តសញ្ញាណឯកសារ និងវត្ថុតាងផ្សេងៗដែលខ្លួនពិចារណាថា ពាក់ព័ន្ធនឹងដំណាក់កាលដំបូងនៃសវនាការ[5]។ ជាការឆ្លើយតបទៅនឹងដីកាសម្រេចរបស់អង្គជំនុំជម្រះនេះ មេធាវីការពារក្តីបានបដិសេធមិនព្រមកំណត់អត្តសញ្ញាណឯកសារជាក់លាក់ណាមួយ ដើម្បីបង្ហាញនៅពេលសវនាការទេ។ ផ្ទុយទៅវិញ មេធាវីការពារក្តីបានតវ៉ាថា ដីកាសម្រេចរបស់អង្គជំនុំជម្រះ គឺផ្ទុយទៅនឹងមាត្រា៣៣៤នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (“CCCP”) និងសូមរក្សា “សិទ្ធិ” ក្នុងការដាក់បង្ហាញឯកសារផ្សេងៗក្នុងពេលណាមួយនៃសវនាការជំនុំជម្រះនៅពេលក្រោយៗទៀត[6]។

៤- នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានមួយជូនអង្គជំនុំជម្រះសាលាដំបូង ដែលនៅក្នុងសេចក្តីសន្និដ្ឋាននេះ សហព្រះរាជអាជ្ញាបានធ្វើការកត់សម្គាល់អំពីការមិនព្រមអនុវត្តតាម “ដោយចេតនា និងដោយគ្មានការសុំទោស” របស់មេធាវីការពារក្តី ចំពោះដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងបានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ប្រាមចោលមេធាវីការពារក្តីជាមុនកុំឲ្យបង្ហាញឯកសារណាមួយនៅពេលសវនាការជំនុំជម្រះ បើសិនឯកសារនោះមិនបានកំណត់

[4] **E9** ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ១៧ មេសា ២០១១។

[5] **E1/4.1** ប្រតិចារិកនៃសវនាការបឋមជាសាធារណៈ, ២៧ មិថុនា ២០១១, ត្រង់ទំព័រទី២៥។

[6] **E9/26** ការជូនដំណឹងអំពីការចូលរួមជាមួយនឹងសារណាបឋមរបស់ អៀង សារី ទាក់ទងនឹងឯកសារដែលត្រូវលើកយកមកសំអាងនៅសវនាការ & សារណាបន្ថែមទាក់ទងនឹងឯកសារថ្មី, ១៩ មេសា ២០១១ និង **E109/3** ការកត់សម្គាល់អំពីឯកសារដែលពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូង, ២២ កក្កដា ២០១១។

អត្តសញ្ញាណស្របតាមដីកាសម្រេចនេះទេ[7]។ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញអនុស្សរណៈមួយដែលនៅក្នុងអនុស្សរណៈនេះ អង្គជំនុំជម្រះសាលាដំបូងបានយោងសំដៅលើសំណើរបស់សហព្រះរាជអាជ្ញា និងថែមទាំងបានស្នើថាឯកសារទាំងឡាយណាដែលមិនបានកំណត់អត្តសញ្ញាណ ស្របតាមកាលបរិច្ឆេទកំណត់របស់អង្គជំនុំជម្រះសាលាដំបូង អាចនឹងត្រូវបានទទួលយកនៅពេលសវនាការជំនុំជម្រះ បើសិនជាភាគីដែលស្នើអាចបង្ហាញឲ្យឃើញថា ឯកសារទាំងនោះមិនអាចឲ្យគេបង្ហាញបានតាំងពីដំបូង ដោយមានការបង្ហាញឲ្យឃើញអំពីការប្រើប្រាស់នូវការព្យាយាមយ៉ាងហ្មត់ចត់ និងថាវាជាផលប្រយោជន៍នៃយុត្តិធម៌សម្រាប់ឯកសារដែលនឹងត្រូវទទួលយកនោះ[8]។

៥- នៅក្នុងអនុស្សរណៈដដែលនេះ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យភាគីនានាដាក់នូវបញ្ជីឯកសារមួយដែលពួកគេទាមទារសុំ ដើម្បីឲ្យទទួលយកទាក់ទងនឹងសាក្សី និងដើម្បីណ្តឹងរដ្ឋប្បវេណីនានាដែលអាចនឹងត្រូវកោះហៅនៅក្នុងអម្ពុងវគ្គទីមួយនៃសវនាការលើកដំបូង[9]។ ជាថ្មីម្តងទៀត មេធាវីការពារក្តីខកខានមិនបានអនុវត្តតាមដីកាបង្គាប់នេះ ដោយបញ្ជាក់ឡើងវិញជាដដែលៗ អំពីជំហររបស់ខ្លួនថាតាមច្បាប់គ្មានលក្ខខណ្ឌតម្រូវឲ្យធ្វើដូច្នេះទេ[10]។ ផ្ទុយទៅវិញ ដោយផ្អែកលើមូលដ្ឋានសូចនា និងបណ្តោះអាសន្នទាំងស្រុង មេធាវីការពារក្តីបានផ្តល់នូវព័ត៌មានទូទៅទាក់ទងនឹងប្រភេទឯកសារដែលខ្លួនមានបំណងបញ្ចូលនៅក្នុង "ពេលវេលាដ៏សមស្រប"[11]។ កាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០១២ មេធាវីការពារក្តីបានបញ្ជាក់ជាដដែលឡើងវិញនូវបំណងរបស់ខ្លួន ចង់ដាក់ជូននូវប្រភេទនៃឯកសារ

[7] **E109/5** សំណើពាក់ព័ន្ធនឹងការខកខានជាលើកទីពីររបស់ នួន ជា ក្នុងការមិនបានអនុវត្តតាមដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីផ្តល់បញ្ជីឯកសារ និងវត្ថុតាងដែលខ្លួនមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ៥ សីហា ២០១១ ("សំណើរបស់សហព្រះរាជអាជ្ញា")។ សូមអានផងដែរ **E109/5/2** *ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបរបស់ នួន ជា ពាក់ព័ន្ធនឹងការខកខានជាលើកទីពីររបស់គាត់ ក្នុងការមិនគោរពតាមដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងដើម្បីផ្តល់នូវបញ្ជីឯកសារ និងវត្ថុតាងដែលគាត់មានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ២២ សីហា ២០១១ ("ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា")*។

[8] **E131/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា *បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង, ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5*, ២៥ តុលា ២០១១ ត្រង់ទំព័រទី៤ (ច្បាប់ចម្លងមួយច្បាប់នៃអនុស្សរណៈដែលបានផ្តល់ជូនជាមុនគ្រាន់ជាការគួរសម ត្រូវបានគេធ្វើការប្រាស្រ័យទាក់ទងមកភាគីនានាតាមរយៈអ៊ីម៉ែល នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១)។

[9] *កន្លែងដូចគ្នានឹងខាងលើ* ,ទំព័រ១។

[10] ឯកសារលេខ **E131/1/9** ការជំទាស់, សេចក្តីសង្កេត និងការជូនដំណឹងស្តីពីឯកសារផ្សេងៗដែលត្រូវដាក់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៤ វិច្ឆិកា ២០១១ ("ការជំទាស់, សេចក្តីសង្កេត និងការជូនដំណឹងរបស់ នួន ជា") ត្រង់កថាខណ្ឌទី១៤,១៥, និងទី២៧។

[11] *កន្លែងដូចគ្នានឹងខាងលើ* , ត្រង់កថាខណ្ឌទី២៨-៣៤។

ទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះនៅពេលណាមួយ[12]។ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ នៅទីបំផុត មេធាវីការពារក្តីបានដាក់នូវបញ្ជីឯកសារដែលបានប្រាប់មុនថាបម្រុងនឹងដាក់ នៅក្នុងពេលទន្ទឹមគ្នានោះ បានរក្សា "សិទ្ធិ" ក្នុងការពឹងផ្អែកទៅលើឯកសារបន្ថែមចំនួនណាមួយ នៅពេលណាមួយក្នុងអំឡុងពេលនៃសវនាការ[13]។

## III. អំណះអំណាង

### ក. មេធាវីការពារក្តីមិនបានផ្តល់យុត្តិកម្មស្របតាមច្បាប់ណាមួយចំពោះការដែលខ្លួនបដិសេធមិនអនុវត្តតាមដីកាបង្គាប់ឲ្យដាក់បញ្ជីឯកសាររបស់អង្គជំនុំជម្រះពីលើកមុន

៦- ដូចដែលបានកត់សម្គាល់ខាងលើ អង្គជំនុំជម្រះបានសម្រេចរួចហើយថា ភាគីទាំងឡាយដែលមានបំណងពឹងផ្អែកលើឯកសារនានាដែលមិនត្រូវបានកំណត់អត្តសញ្ញាណស្របតាមដីកាបង្គាប់របស់អង្គជំនុំជម្រះកាលពីមុនៗមក គួរចាំបាច់ត្រូវតែបង្ហាញឲ្យឃើញថា កាលពីមុននេះឯកសារទាំងនេះមិនអាចឲ្យធ្វើការបានបង្ហាញជូនដោយវីរិយភាពបានទេ និងថាឯកសារទាំងនេះគួរតែត្រូវបានទទួលយកដើម្បីជាផលប្រយោជន៍ដល់យុត្តិធម៌[14]។ ក្នុងការដាក់បញ្ជីឯកសារនាពេលនេះ ដែលមានរយៈពេលជាងប្រាំបួនខែក្រោយកាលបរិច្ឆេទដែលបានកំណត់ពីដំបូងហើយនោះ មេធាវីការពារក្តីមិនបានផ្តល់នូវសេចក្តីបញ្ជាក់ណាមួយ ដើម្បីការធ្វើយុត្តិកម្មចំពោះការខកខានរបស់ខ្លួនកាលពីមុនមកដែលមិនបានកំណត់អត្តសញ្ញាណថាតើឯកសារណាខ្លះដែលខ្លួនមានបំណងពឹងផ្អែកលើ នៅក្នុងពេលសវនាការ។ ផ្ទុយទៅវិញ នៅក្នុងការដាក់ឯកសាររបស់ខ្លួន មេធាវីការពារក្តីបានជជែកតវ៉ាចំពោះការសម្រេចរបស់អង្គជំនុំជម្រះថា "មានលក្ខណៈប្រឆាំងនឹងលិខិត និងស្មារតី" នៃមាត្រា៣៣៤ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលខ្លួនបានប្រកែកតវ៉ាថា គ្មានការតម្រូវឲ្យភាគីនានាក្នុងការផ្តល់ជាមុននូវការជូនដំណឹងអំពីឯកសារដែលពួកគេមានបំណងពឹងផ្អែកលើ នៅក្នុងពេលសវនាការនោះឡើយ[15]។

---

[12] ឯកសារលេខ **E131/1/12** ការជំទាស់ចំពោះឯកសារ និងការដាក់ឯកសារបន្ថែមអនុលោមតាមវិធាន៩២ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី៥ មករា ២០១២, ត្រង់កថាខណ្ឌទី៤-៥។

[13] ឯកសារលេខ **E131/1/13** បញ្ជីឯកសារ, កំណត់សម្គាល់លេខ១ *ខាងដើម* ត្រង់កថាខណ្ឌទី៩។

[14] ឯកសារលេខ **E131/1** អនុស្សរណៈ, កំណត់សម្គាល់លេខ៨ *ខាងដើម* ត្រង់ទំព័រ៤។

[15] ឯកសារលេខ **E131/1/13** បញ្ជីឯកសារ, កំណត់សម្គាល់លេខ១ ខាងដើម ត្រង់កថាខណ្ឌទី៥-៦។

៧- ការលើកសំអាងថា នៅក្នុងករណីមានជម្លោះពិតប្រាកដ ឬជាក់ស្តែងស្តីពីវិធាននៃនីតិវិធីនោះ បទប្បញ្ញត្តិទូទៅនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា គឺមានអាទិភាពទៅលើវិធានផ្ទៃក្នុងដែលត្រូវបានបញ្ជាក់ជាក់លាក់ទៅតាមគោលបំណងពិសេស ត្រូវបានច្រានចោលដោយអង្គបុរេជំនុំជម្រះផង និងដោយអង្គជំនុំជម្រះសាលាដំបូងផង។ ដូចដែល អង្គបុរេជំនុំជម្រះបានថ្លែងថានៅក្នុងអត្ថបទខ្លីមួយដែលបន្ទាប់មក ត្រូវបានផ្តល់ការយល់ព្រមដោយអង្គជំនុំជម្រះសាលាដំបូង៖

> *វិធានផ្ទៃក្នុងបានបង្កើតបានជារបបកំណត់មួយនៃច្បាប់ស្តីពីនីតិវិធីដែលមានខ្លួនឯងស្រាប់ដែលទាក់ទងនឹងកាលៈទេសៈដែលមានតែមួយគត់គ្មានពីររបស់ អវតក ...វិធានផ្ទៃក្នុងមិនមែនបង្កើតឡើងដើម្បីប្រឆាំងនឹងក្រមនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា(“CPC”)នោះឡើយ ប៉ុន្តែការផ្តោតរបស់ អវតក មានលក្ខណៈខុសគ្នាគ្រប់គ្រាន់ ពីកិច្ចប្រតិបត្តិការធម្មតារបស់តុលាការព្រហ្មទណ្ឌរបស់កម្ពុជា ដើម្បីអនុញ្ញាតឲ្យមានជាប្រព័ន្ធដែលមានជំនាញឯកទេសមួយ។ ហេតុដូចនេះ វិធានផ្ទៃក្នុងគឺជាឧបករណ៍ដ៏ចំបងដែលលើកឡើងធ្វើជាសេចក្តីយោងដើម្បីកំណត់សម្រេចអំពីនីតិវិធីផ្សេងៗនៅចំពោះមុខ អវតក ករណីបើសិនជាមិនមានការខុសគ្នាណាមួយរវាងនីតិវិធីដែលចែងនៅក្នុងវិធានផ្ទៃក្នុង និងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា[16] ។*

៨- ប្រការដែលមេធាវីការពារក្តីមិនយល់ព្រមជាមួយនឹងការសម្រេចរបស់អង្គជំនុំជម្រះលើបញ្ហានេះហើយ និងប្រកាន់នូវជំហរពីមុនរបស់ខ្លួនដដែលទាក់ទងអំពីឋានានុក្រមនៃវិធាននីតិវិធីជាធរមាន[17] គឺមិនមែនជាមូលដ្ឋានត្រឹមត្រូវតាមច្បាប់ដែលត្រូវផ្អែកលើដើម្បីធ្វើការបង្គាប់ចំពោះដីកាបង្គាប់ស្តីពីការរៀបចំសវនាការរបស់អង្គជំនុំជម្រះនោះឡើយ។ ហេតុដូចនេះ សហព្រះរាជអាជ្ញារក្សាជំហរដដែលនូវជំហរពីមុនរបស់ខ្លួន ដែលជំហររបស់មេធាវីការពារក្តីគួរតែត្រូវបានច្រានចោលជាមុននៅក្នុងដំណាក់កាលនេះ

[16] ឯកសារលេខ **E55/I/8** សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចបដិសេធលើសំណើសុំមោឃភាព, ចុះថ្ងៃទី២៦ សីហា ២០០៨ ត្រង់កថាខណ្ឌទី១៤ (អង្គបុរេជំនុំជម្រះ) ដែលបានលើកសំអាងដោយមានការយល់ព្រមដោយអង្គជំនុំជម្រះនៅក្នុងឯកសារលេខ **E51/14** សេចក្តីសម្រេចលើអញ្ញត្រកម្មបឋមរបស់ នួន ជា ដែលចោទប្រកាន់អំពីអធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុងសម្រាប់ អវតក, ចុះថ្ងៃទី៨ សីហា ឆ្នាំ២០១១ ត្រង់កថាខណ្ឌទី៧។

[17] នៅក្នុងការដាក់ឯកសារកាលពីលើកមុន មេធាវីការពារក្តីបានថ្លែងថា ខ្លួន “មិនយល់ព្រមចំពោះជំហរពីបន្តធ្វើលើចំណុចនេះដោយអង្គជំនុំជម្រះសាលាដំបូង” និងថាខ្លួននឹងបន្តបញ្ជាក់ឡើងវិញដដែលៗអំពីការជំទាស់របស់ខ្លួនដើម្បីជាប្រយោជន៍ដល់ “កំណត់ហេតុក្នុងការធ្វើបណ្តឹងសាទុក្ខជាយថាហេតុណាមួយ”។ លើសពីនេះ មេធាវីការពារក្តីបានបានបំភ្លឺថា “[]ទោះបីជាជំហរដែលមានការភាន់ច្រឡំត្រូវបានបន្តធ្វើទៅមុខទៀតថ្មីៗនេះដោយអង្គជំនុំជម្រះសាលាដំបូងក្តីក៏មេធាវីការពារក្តីនៅតែប្រកាន់ យកនូវ ជំហរពីមុន[របស់ខ្លួន]” ឯកសារលេខ **E131/1/9** ការជំទាស់ ការសង្កេត និងការជូនដំណឹងរបស់ នួន ជា កំណត់សម្គាល់លេខ១០ ត្រង់កំណត់សម្គាល់លេខ៥២ និងកថាខណ្ឌទី២៧។

ដើម្បីកុំឲ្យដាក់បញ្ចូលនូវឯកសារនានាដែលគួរតែត្រូវបានកំណត់អត្តសញ្ញាណតាំងពីមុននេះ បើសិនជាពួកគេមានសុឆន្ទៈស្មោះត្រង់ និងមានការខិតខំប្រឹងប្រែងម៉ត់ចត់ ក្នុងការគោរពអនុវត្តតាមដីកាបង្គាប់របស់អង្គជំនុំជម្រះពិតប្រាកដមែន[18]។

## ខ. មេធាវីការពារក្តីមិនបានធ្វើតាមលក្ខខណ្ឌតម្រូវក្នុងវិធាន៨៧.៤ ស្តីពីការទទួលយកឯកសារ "ថ្មី" ទេ

៩- បន្ថែមលើនេះ សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា មេធាវីការពារក្តីមិនបានធ្វើតាមលក្ខខណ្ឌតម្រូវនៃវិធាន៨៧.៤ នោះទេ ពាក់ព័ន្ធទៅនឹងឯកសារថ្មីចំនួន១២ ដែលមាននៅក្នុងបញ្ជីឯកសារ[19]។ វិធាននេះចែងថា ភស្តុតាងថ្មីអាចត្រូវបានទទួលយកនៅក្រោយពេលបើកសវនាការ កាលណាវាមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ វាតម្រូវឲ្យភាគីដែលស្នើសុំត្រូវ"បញ្ជាក់មូលហេតុ" និងត្រូវធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថាភស្តុតាងនោះពុំអាចរកបាននៅមុនពេលចាប់ផ្តើមធ្វើសវនាការ។

១០- ផ្ទុយទៅនឹងការអះអាងរបស់មេធាវីការពារក្តី ការផ្តល់នូវការរៀបរាប់ដ៏ខ្លីស្តីពីការអះអាងថាមានភាពទាក់ទងនៃឯកសារនីមួយៗដែលបានដាក់ មិនមានន័យថា"ការដាក់ជូននេះមានបញ្ជាក់មូលហេតុ" ដូចដែលវិធានបានតម្រូវនោះឡើយ។ ដូចដែលបានកត់សម្គាល់ខាងលើ មេធាវីការពារក្តីថែមទាំងមិនបានព្យាយាមបង្ហាញថាឯកសារទាំងនោះពុំអាចរកបាននៅមុនពេលការចាប់ផ្តើមធ្វើសវនាការទៀតផង។

## គ. សហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងការពឹងផ្អែកលើឯកសាររបស់មេធាវីការពារក្តីដែលបានដាក់រួចហើយ ឬស្នើសុំដាក់ នៅចំពោះមុខអង្គជំនុំជម្រះទេ

១១- សហព្រះរាជអាជ្ញាសង្កេតឃើញថាមានឯកសារ ៤ ក្នុងចំណោមឯកសារ ៣៥ ដែលមាននៅក្នុងបញ្ជីឯកសារ ត្រូវបានដាក់ ឬស្នើសុំដាក់ នៅចំពោះមុខអង្គជំនុំជម្រះ តាមសំណើផ្ទាល់របស់អង្គជំនុំជម្រះ។ ដោយឡែក ឯកសារ ៣ ក្នុងចំណោមឯកសារនោះ ដែលជាឯកសារដែលមានរៀបរាប់នៅក្នុងកំណត់សម្គាល់ជើងទំព័រនៃកថាខណ្ឌស្តីពីប្រវត្តិសាវតារនៅក្នុងដីកាដំណោះស្រាយគឺគេបានដាក់លេខសម្គាល់

---

[18] សូមអានឯកសារលេខ E109/5 សំណើសុំរបស់សហព្រះរាជអាជ្ញា និងឯកសារលេខ E109/5/2 សេចក្តីសន្និដ្ឋានឆ្លើយតបរបស់សហព្រះរាជអាជ្ញា, កំណត់សម្គាល់លេខ៧ ខាងដើម, សម្រាប់លើកសំអាងដើម្បីគាំទ្រដល់ការដាក់ទណ្ឌកម្មដោយច្រានចោលជាមុន។

[19] ឯកសារ ២៤-៣៥ ក្នុងបញ្ជីឯកសារ។

ថា E3 រួចហើយ[20]។ ឯកសារមួយផ្សេងទៀត ត្រូវបានចុះជាបញ្ជីនៅក្នុងកំណត់សម្គាល់ជើងទំព័រនៃកថាខណ្ឌទី ២២២ នៅក្នុងដីកាដំណោះស្រាយ ពាក់ព័ន្ធទៅនឹងការជម្លៀសដោយបង្ខំ[21]។ យោងតាមដីកាបង្គាប់ពីមុនរបស់អង្គជំនុំជម្រះ ឯកសារនេះនឹងត្រូវបានពិចារណាថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ កាលណាកថាខណ្ឌនោះត្រូវបានអាននៅក្នុងតុលាការ[22]។ បន្ថែមលើនេះ ឯកសារ ១០ ផ្សេងទៀត ដែលមាននៅក្នុងបញ្ជីឯកសារ ក៏មានដាក់នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ដែលបានដាក់កាលពីខែមេសា ឆ្នាំ២០១១ ផងដែរ[23]។ ការណ៍នេះ រួមមានឯកសារ ៨ ដែលមានលេខយោងសំណុំរឿង[24] និងឯកសារចំនួន២ដែលមិនទាន់បានដាក់លេខនៅក្នុងសំណុំរឿង[25]។

១២- ខណៈដែលមានការអះអាងថា មេធាវីការពារក្ដីគួរត្រូវបានច្រានចោលជាមុនមិនឲ្យដាក់ឯកសារនៅដំណាក់កាលនេះ ដែលថាគួរតែអាចមានលទ្ធភាព និងគួរតែត្រូវបានធ្វើការកំណត់អត្តសញ្ញាណពីមុន សហព្រះរាជអាជ្ញាសូមបញ្ជាក់ថា សហព្រះរាជអាជ្ញានឹងមិនជំទាស់ទៅនឹងមេធាវីការពារក្ដីក្នុងការប្រើប្រាស់ឯកសារចំនួន១៤ ដែលបានលើកឡើងនៅខាងលើ នៅពេលសវនាការឡើយ។ ឯកសារទាំងនេះ ត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ពន្ធ ក នៅក្នុងចម្លើយតបនេះ សម្រាប់ភាពងាយស្រួលនៃឯកសារយោង។

---

[20] IS 2.6 ដាក់លេខ E3/49 (ឯកសារ ១ នៅក្នុងបញ្ជីឯកសារ); IS 4.1 ដាក់លេខ E3/20 (ឯកសារ ២ នៅក្នុងបញ្ជីឯកសារ); D313/1.2.2 ដាក់លេខ E3/88 (ឯកសារ ១៦ នៅក្នុងបញ្ជីឯកសារ)។

[21] D178.11 (ឯកសារ ១០ នៅក្នុងបញ្ជីឯកសារ) ត្រូវបានរៀបរាប់នៅក្នុងកំណត់សម្គាល់ជើងទំព័រ ៧៨៥ និង ៧៨៨ ជាការគាំទ្រដល់កថាខណ្ឌទី ២២២ នៃដីកាដំណោះស្រាយ។

[22] សូមអាន **E141** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង, ១៧ វិច្ឆិកា ២០១១ ទំព័រទី ២-៣ និង សូមអាន **E162** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង, ៣១ មករា ២០១២ ត្រង់កថាខណ្ឌទី ៣។

[23] **E9/31** បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់សវនាការ ស្របតាមវិធាន៨០(៣), ១៩ មេសា ២០១១ ("បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា")។

[24] IS 4.25 (ឯកសារ ៣ នៅក្នុងបញ្ជីឯកសារ/ឧសម្ពន្ធ 19.165 នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា); D210/5 (ឯកសារ ១២ នៅក្នុងបញ្ជីឯកសារ/ឧសម្ពន្ធ 12.797 នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា); D210/6 (ឯកសារ ១៣ នៅក្នុងបញ្ជីឯកសារ/ឧសម្ពន្ធ 12. 1097 នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា); D222/1.17 (ឯកសារ ១៤ នៅក្នុងបញ្ជីឯកសារ; ឧសម្ពន្ធ 19.244 នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា); D269/9.1.15 (ឯកសារ ១៥ នៅក្នុងបញ្ជីឯកសារ; ឧសម្ពន្ធ 12.796 នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា); D313/1.2.4 (ឯកសារ ១៧ នៅក្នុងបញ្ជីឯកសារ; ឧសម្ពន្ធ 19.178 នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា); D313/1.2.406 (ឯកសារ ១៨ នៅក្នុងបញ្ជីឯកសារ; ឧសម្ពន្ធ 12.87 នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា); (ឯកសារ ១៩ នៅក្នុងបញ្ជីឯកសារ; ឧសម្ពន្ធ 18.60 នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា)។

[25] ឯកសារ ២២ នៅក្នុងបញ្ជីឯកសារ/ឧសម្ពន្ធ 19.90 នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា; ឯកសារ ២៣ នៅក្នុងបញ្ជីឯកសារ/ឧសម្ពន្ធ 19.89 នៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា។

## IV. **ដំណោះស្រាយដែលស្នើសុំ**

១៣- ចំពោះមូលហេតុទាំងឡាយដូចបានបញ្ជាក់ខាងលើ សហព្រះរាជអាជ្ញាសូមស្នើសុំឲ្យ អង្គជំនុំជម្រះសាលាដំបូង៖

(១) **ច្រានចោល** បញ្ជីឯកសារនោះ, និង

(២) **កត់សម្គាល់ថា** សហព្រះរាជអាជ្ញានឹងមិនជំទាស់ទៅនឹងមេធាវីការពារក្តី ក្នុងការពឹងផ្អែកលើឯកសារផ្សេងពីនេះទៀតចំនួន១៤ ត្រូវបានកំណត់អត្តសញ្ញាណ នៅក្នុងឧបសម្ពន្ធ ក នៅក្នុងចម្លើយតបនេះ ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១២ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Andrew CAYLEY** សហព្រះរាជអាជ្ញា | | [signature] |